មនសិការខ្មែរ
Moneaksekar Khmer
ឆ្នាំទី 09 លេខ 1647 ថ្ងៃ សៅរ៍-អាទិត្យ ទី 20-21 ខែ មេសា ឆ្នាំ 2002

# សម រង្ស៊ី ៖ គេមិនអាចប្រើល្បិចបំបែក បំបាក់គណបក្ស សម រង្ស៊ី បានជាដាច់ខាត


លោក សម រង្ស៊ី មេដឹកនាំគណបក្សប្រឆាំងពេលសម្ភាសន៍ជាមួយអ្នកកាសែត


លោក សម រង្ស៊ី ពេលចុះពីយន្តហោះនៅព្រលានអន្តរជាតិពោធិ៍ចិនតុង

ដោយ ៖ ជួម ប្រហារ

កាលពីវេលាម៉ោង ១១:២០ នាទីថ្ងៃត្រង់ នៃថ្ងៃទី១៩ មេសា ឆ្នាំ២០០២ម្សិលមិញនេះ លោក *សម រង្ស៊ី* មេដឹកនាំគណបក្សប្រឆាំង នៅក្នុងប្រទេសកម្ពុជា បានវិលត្រឡប់ មកពីបំពេញទស្សនកិច្ច នៅសហរដ្ឋអាមេរិក និងនៅប្រទេសកាណាដា វិញ ហើយ ។ ថ្លែងប្រាប់អ្នកកាសែតជាតិ និងអន្តរជាតិ នៅព្រលាន

តទៅទំព័រទី៤ "ម"

1/3

តមកពីទំព័រទី១ "ម"

យន្តហោះអន្តរជាតិពោធិ៍ចិនតុង លោក *សម រង្ស៊ី* បានបញ្ជាក់ថា ដំណើរទស្សនកិច្ច របស់លោក ទៅកាន់សហរដ្ឋអាមេរិក និង កាណាដា គឺមានគោលបំណងពីរ ។ ក្នុងនោះគោលបំណងទី១ គឺសួរសុខទុក្ខបងប្អូន ជនរួមជាតិយើង ដែលរស់នៅទ្វីបអាមេរិកខាងជើង ហើយនៅចំពេលបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរផងនោះ លោកបានចូលរួមជាមួយពលរដ្ឋយើងនៅច្រើនរដ្ឋ និង ច្រើនក្រុងនៃសហរដ្ឋអាមេរិក ។

ចំណែកគោលបំណងទី២ គឺ លោក បានជួបជាមួយថ្នាក់ដឹកនាំសហរដ្ឋអាមេរិក នៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី ។ ក្នុងនោះ លោកបានជួបជាមួយឧបការីប្រធានាធិបតី ទទួលបន្ទុកកិច្ចការអាស៊ី, ជួបជាមួយឧបការីរបស់អនុប្រធានាធិបតី, ជួបជាមួយនឹងលោកអនុរដ្ឋមន្ត្រី ក្រសួងការបរទេស, ជួបជាមួយសមាជិកសភា និងព្រឹទ្ធសភាសហរដ្ឋអាមេរិក ដូចជាព្រឹទ្ធសមាជិក *ចន ម៉ាក់ខេន* ជាដើម ព្រមទាំងជួបជាមួយសហការី សមាជិកព្រឹទ្ធសភា និងរដ្ឋសភា ជាច្រើនរូបទៀត ដែលគេគិតគូរអំពីប្រទេសកម្ពុជា ។

ឆ្លើយតបនឹងសំណួរ ដែលសួរថា តើលោកបានលើកអំពីបញ្ហាអ្វីខ្លះ ពេលជួបជាមួយមន្ត្រីជាន់ខ្ពស់សហរដ្ឋអាមេរិក ទាំងក្រសួងការបរទេស ក៏ដូចជាជំនួយការប្រធានាធិបតី ?

លោក *សម រង្ស៊ី* បានអះអាងថា «ខ្ញុំបានស្នើសុំឱ្យសហរដ្ឋអាមេរិក ជាពិសេសរដ្ឋាភិបាល របស់លោកប្រធានាធិបតី *ចច ដាប់បិលយូ ប៊ូស* យកចិត្តទុកដាក់ចំពោះបញ្ហាកម្ពុជា ព្រោះតាំងពីលោកបានជាប់ឆ្នោតជាងមួយឆ្នាំមកហើយ លោកមិនទាន់បានបញ្ចេញគោលជំហរអ្វីដែលខុសពីរដ្ឋាភិបាលមុននោះឡើយ គឺមិនទាន់ឃើញសញ្ញាណាមួយដែលបញ្ជាក់ថា រដ្ឋាភិបាលអាមេរិក នឹងអនុវត្តនយោបាយថ្មីមួយចំពោះកម្ពុជា ជាពិសេសលទ្ធិប្រជាធិបតេយ្យ អោយកាន់តែខ្លាំងក្លាថែមទៀត ហើយជួយដល់កម្លាំងប្រជាធិបតេយ្យ នៅកម្ពុជា ។ ខ្ញុំសង្ឃឹមថា សំណើរបស់ខ្ញុំ នឹងត្រូវគេចាប់អារម្មណ៍ រួចធ្វើអោយប្រែប្រួលនយោបាយសហរដ្ឋអាមេរិក ចំពោះកម្ពុជា ហើយថា អាមេរិកមិនបំភ្លេចកម្ពុជាទេ ទោះបីអាមេរិកមានកង្វល់ធំៗជាច្រើន នៅលើពិភពលោកក៏ដោយ ។ ក្នុងនោះប្រទេសកម្ពុជា នឹងស្ថិតនៅក្នុងចំណោមបញ្ហា ដែលសហរដ្ឋអាមេរិក ជំរុញអោយរកដំណោះស្រាយ ចំពោះលទ្ធិប្រជាធិបតេយ្យ និងការរៀបចំបោះឆ្នោតសំរាប់ឆ្នាំ២០០៣ខាងមុខ» ។

ពាក់ព័ន្ធនឹងបញ្ហាបង្កើតតុលាការកាត់ទោសខ្មែរក្រហមលោក *សម រង្ស៊ី* បានរៀបរាប់ថាមន្ត្រីរដ្ឋាភិបាលអាមេរិក មានយោបល់ពីរនៅក្នុងរឿងនេះ ។ ទី១- ត្រូវតែបញ្ឈប់ការចរចា ជាមួយរដ្ឋាភិបាលភ្នំពេញសព្វថ្ងៃ ហើយគាំទ្រអង្គការសហប្រជាជាតិក្នុងគោលជំហរមិនសហការជាមួយរបបមួយដែលខ្វះភាពស្មោះត្រង់ ដែលមិនចង់អោយមានការកាត់ទោសមេខ្មែរក្រហម អោយបានត្រឹមត្រូវ ។ ហើយយោបល់ទី២ គេថា ត្រូវបើកទ្វារចំហបន្តិចទៀតសិនទៅ ព្រោះការកាត់ទោស ទោះបីជាមានចំណុចខ្វះខាតយ៉ាងណា យើងសង្ឃឹមថា នឹងដាក់សម្ពាធទៅលើរដ្ឋាភិបាលភ្នំពេញសព្វថ្ងៃ អោយធ្វើសម្បទាន ចំពោះអង្គការសហប្រជាជាតិ រហូតទៅដល់ការកាត់ទោសនោះ មានភាពអាចនឹងបំពេញបាននូវលក្ខខណ្ឌ និងស្តង់ដារអន្តរជាតិ ចំពោះយុត្តិធម៌ ។ ហើយបញ្ហាសំខាន់គេគ្មានជំនឿលើរបប *ហ៊ុន សែន* ទេ ហើយថា ដរាបណា *ហ៊ុន សែន* នៅតែកាន់អំណាចគេមិនអាច ធ្វើការកាត់ទោសខ្មែរក្រហមប្រកបដោយយុត្តិធម៌ឡើយ រួចអង្គការសហប្រជាជាតិ នឹងមិនមកលេងល្បែងជាមួយរដ្ឋាភិបាល *ហ៊ុន សែន* ទេ ។

ជុំវិញ ការបែកបាក់ផ្ទៃក្នុងគណបក្ស លោក *សម រង្ស៊ី* បានអះអាងថា រឿងនេះលោកបានដឹងទាំងអស់ ហើយវាប្រៀបដូចជារឿងខ្យល់ព្យុះ នៅក្នុងកែវទឹក ។ ព្រោះគណបក្សជាតិខ្មែរកាលពីមុន និងគណបក្ស សម រង្ស៊ី បច្ចុប្បន្ននេះ បានឆ្លងកាត់នូវព្រឹត្តិការណ៍ធំៗ និងលំបាកៗជាងនេះច្រើនណាស់ ។ កាលណោះ *ហ៊ុន សែន* បានទទួលស្គាល់ *ងួន សឿវ* ជាប្រធានគណបក្សជាតិខ្មែរ ក្នុងខណៈ

ដែលខ្ញុំជាប្រធានគណបក្សស្រប ច្បាប់ ។ ប៉ុន្តែល្បិចកលរបស់ *ហ៊ុន សែន* ដែលចង់បំបែកបំបាក់គណបក្សជាតិខ្មែរ កាលពីមុន និងគណបក្ស សម រង្ស៊ី នៅពេលនេះ គឺបំបែកបំបាក់មិនបានជាដាច់ខាត ។ ព្រោះអី ៩៩,៩៩% នៃសមាជិកគណបក្ស សម រង្ស៊ី នៅតែគាំទ្រគោលនយោបាយគណបក្ស សម រង្ស៊ី និងប្រធាន *សម រង្ស៊ី* ដដែល ។ លោក *សម រង្ស៊ី* បានសង្កត់ធ្ងន់ថា លោកគ្មានព្រួយបារម្ភចំពោះការបែកបាក់នេះ ទាល់តែសោះ ហើយរឿងនេះ បានដោះស្រាយចប់អស់ហើយ ។

លោក *សម រង្ស៊ី* បានរៀបរាប់អោយដឹងទៀតថា លោកបានបំពេញទស្សនកិច្ច ប្រមាណ ១០រដ្ឋ នៅសហរដ្ឋអាមេរិកនិងទីក្រុងជាច្រើន នៅតាមបណ្តារដ្ឋនីមួយៗ ។ ហើយលោកប្រមូលបានថវិកាជាច្រើនម៉ឺនដុល្លារ សំរាប់ប្រើប្រាស់ ដើម្បីទប់ទល់ក្នុងការបោះឆ្នោតខាងមុខ ។ ក្នុងនោះថវិកាមួយផ្នែក នឹងត្រូវយកទៅជួយអភិវឌ្ឍន៍ ឃុំ-សង្កាត់ ដែលគណបក្ស សម រង្ស៊ី បានឈ្នះឆ្នោត ដើម្បីឱ្យឃុំសង្កាត់នោះ មានការរីកចំរើនជាងឃុំ-សង្កាត់ដទៃទៀត ។ ការអភិវឌ្ឍន៍ឃុំ-សង្កាត់ ដែលគណបក្ស សម រង្ស៊ី ឈ្នះឆ្នោត គឺចង់បង្ហាញអោយឃើញថាជាឃុំ-សង្កាត់ ដែលមានលទ្ធិប្រជាធិបតេយ្យ មានសិទ្ធិសេរីភាព និងមានលក្ខណៈត្រឹមត្រូវ ។

លោក *សម រង្ស៊ី* បានអះអាងទៀតថា លោកនឹងដាក់ឈ្មោះវីរបុរសខ្មែរមួយចំនួនដែលបានចាប់ផ្តើមប្រយុទ្ធប្រឆាំងជាមួយបរទេសឈ្លានពាន កាលពីឆ្នាំ១៩៧៩ ទៅលើផ្លូវក្នុងសង្កាត់ដែលដឹកនាំ ដោយមន្ត្រីគណបក្ស សម រង្ស៊ី ។ ហើយលោកនឹងដាក់ឈ្មោះផ្លូវ *គង់ ស៊ីលាស់* នៅក្នុងសង្កាត់មួយ នាទីក្រុងភ្នំពេញ ទៅលើផ្លូវដែលមានតែលេខក្នុងពេលកន្លងមក ព្រោះអ្នកណាក៏ស្គាល់ដែរថា លោក *គង់ ស៊ីលាស់* ជាមេទ័ពមួយរូប ដែលហ៊ានចេញមុខមុនគេ ប្រឆាំងបរទេសឈ្លានពាន កាលពីឆ្នាំ១៩៧៩ ។ បន្ទាប់មកលោកនឹងដាក់ឈ្មោះផ្លូវមួយចំនួនទៀត ដូចជាផ្លូវ *ហួ ស៊ុខ, ចៅ សម្បត្តិ, ភ្លួច យឿម* ជាដើម ។

លោក *សម រង្ស៊ី* បានថ្លែងនៅចំពោះមុខ អ្នកកាសែតជាតិ និងអន្តរជាតិទៀតថា លោកគ្រោងនឹងស្ថាបនា វិមានមួយ នៅទីក្រុងភ្នំពេញ ក្នុងសង្កាត់មួយ ដែលគណបក្ស សម រង្ស៊ី ជាអ្នកដឹកនាំ ដើម្បីអោយប្រជាពលរដ្ឋរំលឹកគុណវីរបុរស ដែលប្រឆាំងបរទេសឈ្លានពាន ។ ដោយហេតុថា កន្លងមកយើងឃើញមានតែស្តូបឃ្មួន ប៉ុណ្ណោះ អត់ដែលឃើញ មានស្តូបគោរពដល់វីរបុរសខ្មែរ អ្នកតស៊ូដែលប្រឆាំងនឹងបរទេសឈ្លានពានទាល់តែសោះ ។ គំរោងនេះបានទទួលការគាំទ្រយ៉ាងខ្លាំង ហើយលោកនឹងចាប់ផ្តើម ពីពេលនេះតទៅ ព្រោះអីលោកប្រមូលបានថវិកាគ្រប់គ្រាន់ សំរាប់កសាងស្តូបនេះរួចហើយ ដោយស្តូបនេះនឹងត្រូវកសាង នៅតាមផ្លូវជាតិសំខាន់មួយដើម្បីងាយស្រួលប្រជាពលរដ្ឋ គោរពវិញ្ញាណក្ខន្ធចំពោះវីរជនខ្មែរស្នេហាជាតិ ៕

---

3/3